ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ៧៧២/២៣ ក.ធ.សសណា

ថ្ងៃ ពុធ ៤ កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២៣

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំបុណ្យកឋិនទាន

**យោង៖** លិខិតលេខ ១១/២០២៣ គជបអ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។

ក្រសួងធម្មការ និងសាសនា មានកិត្តិយសសូមទូលថ្វាយ ប្រគេន សម្តេច ព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជម្រាបជូនគ្រប់មន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ព្រះមេត្តា-មេត្តាជ្រាបថា **បុណ្យកឋិនទាន** ជាកាលទានមួយដ៏ថ្លៃថ្លា មានលក្ខណៈពិសេសនៅក្នុងព្រះពុទ្ធសាសនា ដែលក្នុងមួយឆ្នាំមានតែម្តង មានរយៈពេលកំណត់តែ ២៩ថ្ងៃ ដោយវត្តមួយទទួលបានតែអង្គកឋិនមួយ ជាទានមានផលានិសង្សច្រើន ជាទីជ្រះថ្លានិងចំណូលចិត្តរបស់ពុទ្ធបរិស័ទខ្មែរ ដែលតែងតែប្រារព្ធធ្វើឡើងរៀងរាល់ឆ្នាំ។ ក្រៅពីនេះ តាមរយៈកឋិនទាន វត្តនីមួយៗក៏មានលទ្ធភាព អាចនឹងទទួលបាននូវសម្ភារៈ ថវិកា សម្រាប់បម្រើការកសាងទីសេនាសនៈនៅក្នុងវត្ត មានព្រះវិហារ កុដិ សាលា និងជួយឧបត្ថម្ភដល់ការកសាងសមិទ្ធផលសង្គម និងវិស័យសង្គមកិច្ចថែមទៀតផង។ **ឆ្នាំនេះ កឋិនទាន** នឹងប្រព្រឹត្តទៅពីថ្ងៃ១រោច ខែអស្សុជ ដល់ថ្ងៃ១៥កើត ខែកត្តិក ត្រូវនឹងថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

ដើម្បីរៀបចំបុណ្យកឋិនទាន ឱ្យដំណើរការ និងប្រព្រឹត្តទៅស្របតាមទំនៀមទម្លាប់ និងប្រពៃណីព្រះពុទ្ធសាសនា ក្រសួងធម្មការ និងសាសនា សូមធ្វើការណែនាំដល់គ្រប់មន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ដូចតទៅ៖

-ត្រូវយកចិត្តទុកដាក់បង្កលក្ខណៈឱ្យបានល្អប្រសើរ ប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ ប្រារព្ធពិធីកឋិនទាន ស្របតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត។

-គ្រប់វត្តអារាម ត្រូវរៀបចំសម្អាតទីតាំងវត្តអារាម ផ្លូវថ្នល់ បូជនីយដ្ឋាន ដោយតុបតែងលម្អ បំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក ពាក្យអប់រំ និងពុទ្ធភាសិតនានាឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន។

សួនច្បារសម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីមែល : ministry religion@yahoo.com Web site : www.mocar.gov.kh

-គ្រប់វត្តអារាមនីមួយៗ ប្រសិនបើទេយ្យវត្ថុ មានភោជនាហារ និងចំណីជាដើម លើសពីសេចក្តីត្រូវការ គួរចាត់ចែងរៀបចំជូនដល់ចាស់ព្រឹទ្ធាចារ្យ កុមារកំព្រា ជនពិការ និងជនងាយរងគ្រោះផ្សេងៗទៀត។

-ហាមដើររែអង្គាសនៅតាមផ្លូវសាធារណៈ និងទីប្រជុំជនជាដើម ដែលធ្វើឱ្យបាត់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងកិត្តិយសព្រះពុទ្ធសាសនា។

សូមលោកប្រធានមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ពាក់ព័ន្ធ ព្រះមេគណ ព្រះអនុគណ និងព្រះចៅអធិការវត្ត អនុវត្តសេចក្តីណែនាំនេះឱ្យបានសម្រេចលទ្ធផល ល្អប្រសើរ ស្របតាមប្រពៃណីជាតិដ៏រុងរឿង។

រដ្ឋមន្ត្រី

ចាយ បុរិន

**ចម្លងជូន-ជូន៖**

-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
-សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ
-ខុទ្ទកាល័យសម្តេចអធិបតីនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ-អន្តរជាតិ
"ដើម្បីថ្វាយ-ជូនជ្រាប"
-រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
"ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ